# ព្រះវិហារវត្តមុនីសាគរ

វត្តមុនីសាគរស្ថិតនៅក្នុងសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ វត្តនេះស្ថិតក្នុងបណ្ដាវត្តចាស់ៗតាមបណ្ដោយដងទន្លេមេគង្គប៉ែកខាងកើត ស្របនឹងផ្លូវជាតិលេខ១ ដូចជាវត្តមជ្ឈឹមវ័ន វត្តចំប៉ា និងវត្តកៀនស្វាយក្នុងជាដើម។ ក្នុងបរិវេណវត្តមុនីសាគរ គេឃើញមានព្រះវិហារជាសំណង់បុរាណដ៏ល្អវិចិត្រ កសាងអំពីឈើនិងកំបោរបាយអយ៉ាងល្អវិចិត្រ (រូបលេខ១)។ នៅលើព្រះវិហារនេះ ពុំឃើញមានចំណារ ឬកស្ដុតាងអ្វីបញ្ជាក់ថាព្រះវិហារកសាងនៅក្នុងឆ្នាំណាឡើយ។ ប៉ុន្តែ *Daniel Guéret* និង *Dominique-Pierre Guéret* ដែលជាអ្នកសិក្សាស្រាវជ្រាវអំពីវត្តអារាមក្នុងសង្គមខ្មែរយល់ថា ព្រះវិហារវត្តមុនីសាគរកសាងឡើងតាំងពីដើមសតវត្សទី២០។[៧] ចំពោះសន្ទឹកសីមា គំនូរ និងក្បាច់លម្អផ្សេងៗនៃព្រះវិហារនេះ គឺជាប្រធានបទយ៉ាងសំខាន់គួរឱ្យសិក្សាស្វែងយល់។



រូបលេខ១ ព្រះវិហារវត្តមុនីសាគរ

[៧] *Daniel Guéret & Dominique-Pierre Guéret 2017: 95*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ព្រះវិហារវត្តមុនីសាគរ បានកសាងនៅលើខឿនបីថ្នាក់ ដែលមានជណ្ដើរឡើងគ្រប់ទិសទាំងបួន។ ខឿនថ្នាក់ទី១ និងថ្នាក់ទី២ លម្អជារូបនាគព័ទ្ធជាបង្កាន់ដៃជុំវិញ ហើយនៅអមជណ្ដើរនីមួយៗនៃខឿនទី៣ លម្អដោយតោមួយគូ។ ចំពោះគ្រឿងបង្គុំដំបូលគឺជាឈើ ហើយផ្ទៃដំបូលព្រះវិហារគេប្រក់ប្រភេទក្បឿងរលោង (ឬអ្នកស្រុកខ្លះហៅថាក្បឿងរាំង) រាងជ្រាលចុះសងខាងបីថ្នាក់ៗ នៅលើចុងព្រំដំបូលខាងមុខមានបំពាក់លម្អដោយជហ្វាពីរ ហើយលើចុងព្រំដំបូលខាងក្រោយលម្អដោយជហ្វាពីរដែរ។ បើផ្អែកតាមការសិក្សាបែងចែងរបស់អ្នកស្រាវជ្រាវ ប្រភេទសំណង់ព្រះវិហារបែបនេះ គេចាត់ចូលក្នុងទម្រង់ព្រះវិហារជហ្វាបួន ឬគេហៅថាព្រះវិហារបុរាណ។[២] ទន្ទឹមនឹងនេះ នៅតាមចុងចែងដំបូលនីមួយៗគេឃើញមានលម្អដោយនាគចែងទាំងអស់ (រូបលេខ២-៣)។




*រូបលេខ២-៣ ទម្រង់ដំបូល និងការលម្អផ្សេងៗនៃព្រះវិហារវត្តមុនីសាគរ*

អរិយធម៌ខ្មែរ KHMER CIVILIZATION

ចំពោះការរចនាតុបតែងលម្អនៅលើរចនាសម្ព័ន្ធសំណង់ផ្នែកខាងក្រោមដំបូល (ខាងក្រៅជញ្ជាំង) គេឃើញនៅតាមរងស្បូវជុំវិញលម្អដោយក្បាច់រចនាយ៉ាងរស់រវើកឆ្លាក់អំពីឈើ។ មិនតែប៉ុណ្ណោះ គេសម្គាល់ឃើញថាសសរបាំងសាចជុំវិញព្រះវិហារនេះ ក៏ជាសសរឈើមានរាងបួនជ្រុង ដែលកម្រឃើញមានសល់នៅតាមបណ្ដាព្រះវិហារបុរាណផ្សេងៗ។ នៅតាមក្បាលសសរនីមួយៗជុំវិញទាំងបួនទិស សុទ្ធតែលម្អដោយរូបកិន្នរ។ ចំណែកឯនៅក្បាលសសរទ្រចុងចែងដំបូលទាំងបួនជ្រុង លម្អដោយរូបគ្រុឌយ៉ាងអង់អាច (រូបលេខ៤-៥)។

[២] សូមអានបន្ថែម៖ ព្រាប ចាន់ម៉ារ៉ា ២០១៧: ១៣-២៣

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត





រូបលេខ២៤-៥ ការលម្អលើរាងស្បូវ និងក្បាលសសជុំវិញបាំងសាច

ចំណែកហោជាងព្រះវិហារនេះ គឺជាហោជាងឆ្លាក់អំពីឈើទាំងពីរផ្ទាំង ដែលមានទិដ្ឋភាពរួមស្មើរដូចគ្នា គឺខាងក្រោមឆ្លាក់ផ្កាឈូករីកដេរដាស ខាងលើរចនាជាក្បាច់ផ្កាភ្ញី។ ហោជាងមុខ មានរូបព្រះពិស្ណុការគង់លើផ្កាឈូកធំមួយកណ្តាលផ្ទៃទឹក ហើយមាននាគមួយគូងើបឡើង មានអណ្តាតចេញមកបែកជាក្បាច់ភ្ញីទេសយ៉ាងរស់រវើកព័ន្ធព័ទ្ធរាយទៅខាងលើ (រូបលេខ២៦)។ ហោជាងក្រោយ មានផ្ទៃកណ្តាលមានស្ទឹកឈូកធំមួយទ្រូបល្ល័ង្ក ហើយលើបល្ល័ង្កនោះមានតម្កល់ឆ័ត្ររួត៧ថ្នាក់។ មិនតែប៉ុណ្ណោះសោត នៅអមបល្ល័ង្កនេះ មានទេព្តាពីរអង្គហោះប្រណម្យដៃសំពះបល្ល័ង្កនោះ ហើយនៅអមឆ័ត្ររួតមានហង្សមួយគូផងដែរ (រូបលេខ២៧)។



រូបលេខ២៦ ហោជាងមុខ



រូបលេខ២៧ ហោជាងក្រោយ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក នៅតាមចន្លោះបាំងសាចខាងក្រៅព្រះវិហារ តាមទិស និងអនុទិសគេឃើញមានដាំសន្ទឹកសីមាព័ទ្ធជុំវិញ ដែលឆ្លាក់ជារូបផ្សេងៗគួរឱ្យកត់សម្គាល់។ សន្ទឹកសីមាទាំងអស់ឃើញនៅសល់តែ៧ប៉ុណ្ណោះ ដ្បិតសន្ទឹកសីមានៅទិសខាងជើងពុំឃើញឡើយ (បាត់?) ឯសន្ទឹកសីមាឥន្ទ្រគីលមុខបល្ល័ង្កព្រះជីវ៍ក៏ពុំឃើញដែរ។ ប៉ុន្តែយ៉ាងណាក្តី គេយល់ថារូបដែលលើកយកមកឆ្លាក់តាមសន្ទឹកសីមានីមួយៗ ជារូបទោសពុំមែនសាច់រឿងជាប់បន្តគ្នាពីមួយទៅមួយទេ។[៣] សន្ទឹកសីមាខាងមុខឈមនឹងព្រះជីវ៍ គេឆ្លាក់ជារូបបុព្វជិត(?) (រូបលេខ៨) ហើយនៅជ្រុងអាគ្នេយ៍ឆ្លាក់រូបនាងគង្ហីងច្បួតសក់(រូបលេខ៩) និងជ្រុងឦសានឆ្លាក់ជារូបព្រះកញ្ញាយ(រូបលេខ១០)។ ចំណែកឯនៅចំហៀងខាងត្បូងឆ្លាក់រូបទេព្តាឈរប្រណម្យ(?)(រូបលេខ១១) ហើយចំពោះសន្ទឹកសីមានៅផ្នែកខាងក្រោយព្រះវិហារវិញ គេឆ្លាក់រូបទេពប្រណម្យតម្កល់កណ្តាល (រូបលេខ១២) អមដោយរូបព្រះសង្ឃធុតង្គ(?) នៅជ្រុងនិរតី (រូបលេខ១៣) និងរូបហនុមាននៅជ្រុងពាយ័ព្យ (រូបលេខ១៤)។



*រូបលេខ៨-១៤ រូបផ្សេងៗឆ្លាក់លើសន្ទឹកសីមាព្រះវិហារវត្តមុនីសាគរ*

រីឯនៅខាងក្នុងព្រះវិហារ គេសង់ឡើងឱ្យមានល្វែងសំខាន់ៗបីល្វែងគឺ ល្វែងគ្រឹះនៅកណ្តាល និងរបៀងអមសងខាងដូចព្រះវិហារបុរាណនានាដែរ។ ត្រង់ចន្លោះល្វែងគ្រឹះចុងខាងលិច គឺជាបល្ល័ង្កព្រះជីវ៍ដែលសង់ខ្ពស់ (រូបលេខ១៥)។ ព្រះជីវ៍អង្គនេះ ពុំដឹងថាកសាងឡើងតាំងពីឆ្នាំណាឡើយ តែគេសាងឡើងជាទម្រង់ព្រះបដិមាផ្ចាញ់មារ គង់ភ្នែនព្រះហត្ថស្តាំដាក់លើព្រះបាទស្តាំ ចុងព្រះហស្តសំយុងចុះក្រោម និងព្រះហស្តឆ្វេងផ្ងារដាក់លើព្រះបាតឆ្វេង។

ការលម្អខាងក្នុងព្រះវិហារ នៅត្រង់ផ្នែកសំខាន់ៗនៃសំណង់ដូចជាពិតាន សសរ និងជញ្ជាំង។ ពិតានព្រះវិហារនេះ សាងពីឈើចំខាងលើល្វែងគ្រឹះ ហើយមានគំនូរទឹបទឹក

[៣] សូមអានបន្ថែម៖ ស៊ីយ៉ុន សុភារិទ្ធ ២០១០-២០១១: ៥៦-៥៩

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

មាសជាក្បាច់រង្វង់ធំៗ ពោលគឺពុំមានគំនូររូបអ្វីឡើយ។ ចំណែកឯនៅលើផ្ទៃជញ្ជាំងជុំវិញ គឺជាគំនូរសាច់រឿងពុទ្ធប្រវត្តិ ដែលគេសាងជាផ្ទាំងធំៗរៀបរាប់ចេញពីព្រះពុទ្ធចូលនិព្វាន នៅលើជញ្ជាំងខាងកើត (រូបលេខ១៦) ហើយរាយបន្តបន្ទាប់មកទៀតដូចជាចែកព្រះបរមសារីរិកធាតុ ប្រសូត្រ សម្ដែងឫទ្ធិ ទតសួន អភិសេក ចេញបួស ទុក្ករកិរិយា ត្រាស់ដឹង... ហូរហែរហូតមកដល់ព្រះអង្គទ្រង់ប្រឈូន។



រូបលេខ១៥ ព្រះជីវ័ក្នុងព្រះវិហារវត្តមុនីសាគរ



រូបលេខ១៦ លក្ខណៈគំនូរពុទ្ធប្រវត្តិក្នុងព្រះវិហារ

ប៉ុន្តែយ៉ាងណាក្ដី គំនូរដែលគេយល់ថាមានភាពចំណាស់ និងគួរឱ្យចាប់អារម្មណ៍បំផុតក្នុងព្រះវិហារនេះ គឺគំនូរបុរាណគូរលើគល់សសរទាំងពីរជួរអមល្វែងគ្រឹះ។ គំនូរទាំងនោះ មានទំហំទទឹងប្រហែល២តឹកកន្ទះ កម្ពស់ប្រហែលកន្ទះម៉ែត្រពីគល់សសរ ហើយគេគូរជុំវិញសសរទាំងបួនជ្រុង។ ផ្ទៃសសរខាងលើ គេរចនាជាក្បាច់ទឹបទឹកមាសរហូតទល់នឹងពិតាន (រូបលេខ១៧)។ ចំពោះប្រធានបទរឿងដែលគេលើកយកមកគូរមានពីរសំខាន់គឺ ឈុតខ្លះក្នុងរឿងពុទ្ធប្រវត្តិ និងរឿងផ្សេងៗទៀតក្នុងជាតក។ សាច់រឿងដែលគូរនោះសោតហាក់ដូចជាសង្ខេបខ្លីបំផុត ហើយពុំមានខ្សែរឿងពីដើមដល់ចប់ទេ ពោលគឺលើកយកតែត្រង់ឈុតសំខាន់ៗមកគូរតែប៉ុណ្ណោះ (រូបលេខ១៨-២២)។ គំនូរខ្លះ ហាក់ដូចជាឃើញមានស្នាកស្នាមកោសលុប ដាប់បំផ្លាញ។ ប៉ុន្តែការលើកយកសាច់រឿងជាតកផ្សេងៗមកគូរលើគល់សសរបែបនេះ គេធ្លាប់ឃើញនៅក្នុងព្រះវិហារវត្តពាមមង្គល។[៦]

[៦] សូមអានបន្ថែម៖ "ព្រះវិហារវត្តពាមមង្គលនិងឥទ្ធិលសិល្បៈចិន" ដោយ ហៀន សុវណ្ណមរកត ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/25368 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ១៧ គំនូរលើគល់សសរ



រូបលេខ១៨ ទ្រង់ប្រសូត្រ



រូបលេខ១៩ រឿងព្រះមហាជនក



រូបលេខ២០ រឿងព្រះមហោសថ



រូបលេខ២១ រឿងច័ន្ទកុមារ



រូបលេខ២២ រឿងវេស្សន្តរ

សង្ខេបសេចក្ដីមក ព្រះវិហារវត្តមុនីសាគរ ជាមត៌កដ៏ល្អដែលសេសសល់នូវទឹកដៃស្ថាបត្យកម្មបុរាណ ក្បាច់លម្អ និងគំនូរបុរាណដ៏វិចិត្រ។ គំនិតនៃការបង្ហាញសាច់រឿងតូចៗនៅទីទាបបែបនេះ ហាក់ដូចជាមានចេតនាឱ្យអ្នកមើលងាយស្វែងយល់ជាប់នឹងភ្នែក។ ប៉ុន្តែយ៉ាងណាក្ដី ការស្វែងយល់ស៊ីជម្រៅអំពីសិល្បៈបុរាណនេះ គួរតែបន្តពិនិត្យលម្អិតបន្ថែមទៀត។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារយោង

ព្រាប ចាន់ម៉ារ៉ា

២០១៧, *សំណង់នៅតាមវត្ត*, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

ស៊ីយ៉ុន សុភារិទ្ធ

២០១០-២០១១, "ចម្លាក់រឿងលើសីមា", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ៦, ទំ.៥៦-៥៩, Friends of Khmer Culture, ភ្នំពេញ

ហៀន សុវណ្ណមរកត

"ព្រះវិហារវត្តពាមមង្គលនិងឥទ្ធិលសិល្បៈចិន" ផ្សាយលើគេហទំព័រ https://ams.com.kh/khmercivilization/detail/25368 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២

Daniel Guéret & Doninique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត